ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ៧២ ត្រីមាសទី ០៣ ឆ្នាំ ២០១៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៧-០៩-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៩១៧/៦៩១ ស្តីពី ការបញ្ចប់ភារកិច្ច លោកជំទាវ **កែវ សុធារី** ពីអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៅក្រសួងធម្មការ និងសាសនា ដោយរក្សាទុកក្របខ័ណ្ឌ និងឋានន្តរស័ក្តិនៅដដែល ៧៧២២

២៧-០៩-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៩១៧/៦៩២ ស្តីពី ការសម្រួលភារកិច្ចឯកឧត្តម **ឆេព តិយ្យោវិទ្ធ** ពីអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ មកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧៧២៣

២៩-០៩-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៩១៧/៦៩៤ ស្តីពី ការតម្លើងឋានៈដល់ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០៩ រូប ៧៧២៤

២៩-០៩-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៩១៧/៦៩៥ ស្តីពី ការតម្លើងឋានៈដល់សមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៣៧ រូប ៧៧២៥

២៩-០៩-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៩១៧/៦៩៦ ស្តីពី ការតម្លើងឋានៈដល់ឯកឧត្តម **ហ៊ុន ម៉ានិត** នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន និងតម្លើងឋានៈដល់ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២៨ រូប ៧៧២៧

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

០៦-០៩-២០១៧ -អនុក្រឹត្យលេខ ១៥០ អនក្រ.បក ស្តីពី ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៧៧២៩

០៦-០៩-២០១៧ -អនុក្រឹត្យលេខ ១៥១ អនក្រ.បក ស្តីពី ការទទួលស្គាល់វិទ្យាស្ថានស៊ីអ៊ីអូ ៧៧៣១

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១៥២ អនក្រ.បក ស្តីពី ការបង្កើតទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៧៧៣៤

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៤៦ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ៧៧៥២

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៤៧ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៧៧៥៣

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៤៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៧៥៤

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៤៩ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែង តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ ៧៧៥៥

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥០ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៧៧៥៧

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៧៥៩

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៧៦០

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៧៦១

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៧៦៤

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៧៧៦៧

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៧៦៩

០៨-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៧ អនក្រ.តត ស្តីពី ការជូនមេដាយមាសការងារ ៧៧៧០

១៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៧៧២

១៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៥៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៧៧៣

១៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៧៧៤

១៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៧៧៦

១៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៧៧៧

១៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៧៧៩

-អនុក្រឹត្យលេខ ១០៦៤-១០៦៥ អនក្រ.តត មិនទាន់បានទទួល

២២-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦៦ អនក្រ.តត ស្តីពី ការតែងតាំង និងសម្រួលភារកិច្ចមន្ត្រីរាជការ ៧៧៨០
២២-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦៧ អនក្រ.តត ស្តីពី ការតែងតាំង និងសម្រួលភារកិច្ចមន្ត្រីរាជការ ៧៧៨៣
២៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៧៨៥
២៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៦៩ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៧៧៨៦
២៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៧០ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិវរអគ្គានុរក្ស នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៧៧៨៧
២៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៧១ អនក្រ.តត ស្តីពី ការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៧៨៩
២៥-០៩-២០១៧ -អនុក្រឹត្យលេខ ១០៧២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ តាមកម្រិតសញ្ញាបត្រដល់មន្ត្រីរាជការ ៧៧៩១

២-សេចក្តីសម្រេច

១២-០៩-២០១៧ -សេចក្តីសម្រេចលេខ ៨០ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៧៩៤
១២-០៩-២០១៧ -សេចក្តីសម្រេចលេខ ៨១ សសរ ស្តីពី ការផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៧៩៦

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៦-១២-២០១៦ -ប្រកាសលេខ ១៥៥២ សហវ.ប្រក ស្តីពី ការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ *(តមកពី រាជកិច្ចលេខ ៧១)* ៧៧៩៨
២៦-១២-២០១៦ -ប្រកាសលេខ ១៥៥៤ សហវ.ប្រក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី នៃមាតិកាថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ *(តមកពី រាជកិច្ចលេខ ៧១)* ៧៨០០

ព្រះរាជក្រឹត្យ

នស/រកត/០៩១៧/៦៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : បញ្ចប់ភារកិច្ច លោកជំទាវ **កែវ សុធារី** ពីអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៅក្រសួងធម្មការ និងសាសនា ដោយរក្សាទុកក្របខ័ណ្ឌ និងឋានន្តរស័ក្តិនៅដដែល។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

៧៩ណ.១៧០៩.៧០០

លេខៈ ៦៩៤ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៩១៧/៦៩២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : សម្រួលភារកិច្ចឯកឧត្តម **ធេព តិយ្យោរិទ្ធ** ពីអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ មកជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

ចរឈ.១៧០៩.៧០១

លេខៈ៦៩៥ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ .ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ូយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៩១៧/៦៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជក្រឹត្យ

ត្រាស់បង្គាប់

មាត្រា១ : ដំឡើងឋានៈជូនទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០៩ រូប :

១- ឯកឧត្តម	**ឡាក់**	**ផល្លា**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម	**ឌី**	**កុសល**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម	**ខាំពូន**	**កែវមុណី**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	
៤- ឯកឧត្តម	**ស៊ាង**	**ម៉ុនលាង**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	បន្ថែមលើមុខងារបច្ចុប្បន្ន
៥- ឯកឧត្តម	**ឈឹម**	**សារ៉េត**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	បន្ថែមលើមុខងារបច្ចុប្បន្ន
៦- ឯកឧត្តម	**មួន**	**សារ៉ៃ**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	បន្ថែមលើមុខងារបច្ចុប្បន្ន
៧- ឯកឧត្តម	**ឡាក់**	**ផល្លី**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	បន្ថែមលើមុខងារបច្ចុប្បន្ន
៨- លោកជំទាវ	**ញៀម**	**ស៊ីណាត**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	
៩- ឯកឧត្តម	**ម៉ែន**	**អ៊ាន**	មានឋានៈស្មើ	**រដ្ឋមន្ត្រី**	។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

តារសរ.១៧០៩.៧០៣

លេខ: ៧០១ ស.ណ
សំណៅចម្លងដែលមានអត្ថន័យត្រឹមត្រូវជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៩១៧/៦៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានៈដល់សមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៣៧ រូប ៖

១-ឯកឧត្តម **ហុង ស៊ីណា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២-ឯកឧត្តម **ហូ សិទ្ធីគុណា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៣-លោកជំទាវ **ហូ សុវណ្ណិកា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៤-ឯកឧត្តម **សឹង ស៊ីណា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៥-ឯកឧត្តម **លឹម ប៊ុនហុក**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៦-ឯកឧត្តម **ច្រាជ្ញ សុតត្រា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៧-ឯកឧត្តម **តាំង សាមឿន**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៨-ឯកឧត្តម **នៅ រ៉ា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៩-ឯកឧត្តម **គង់ ចំរើន**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១០-ឯកឧត្តម **ហួយ សិទ្ធិសម្ភា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១១-លោកជំទាវ **ជូ ដារ៉ារ៉េត**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១២-ឯកឧត្តម **គីម សុវណ្ណា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៣-ឯកឧត្តម **យ៉ាត ទូច**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១៤-ឯកឧត្តម **ច្រាជ្ញ សុផល** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៥-ឯកឧត្តម **ឈឹម វាសនា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៦-ឯកឧត្តម **លឹម ឡេង** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៧-ឯកឧត្តម **គីម រិទ្ធី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៨-ឯកឧត្តម **សំលៀង សាលីន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៩-ឯកឧត្តម **ជាវ បុត្រមុនី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២០-ឯកឧត្តម **ម៉ែន ធន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២១-ឯកឧត្តម **ឆុច ដាលីន** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២២-ឯកឧត្តម **សាង បូរ៉ាណា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២៣-ឯកឧត្តម **ហេង សុខណាង** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២៤-ឯកឧត្តម **ហួត ពៅ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៥-ឯកឧត្តម **សេង វណ្ណៈ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៦-ឯកឧត្តម **ពេជ អតិរៈ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៧-ឯកឧត្តម **ហូ វឌ្ឍវឌ្ឍនៈ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៨-ឯកឧត្តម **ជា ពិសី** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៩-ឯកឧត្តម **ហ៊ុន សាអ៊ុន** មានឋានៈស្មើ អគ្គនាយក
៣០-លោកជំទាវ **សម សូនី** មានឋានៈស្មើ អគ្គនាយក
៣១-ឯកឧត្តម **គ្រុយ សេងហ៊ត** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៣២-ឯកឧត្តម **ហាក់ សុទ្ធា** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៣៣-ឯកឧត្តម **ម៉ុនឆៃ ម៉ារីលុច** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៣៤-ឯកឧត្តម **ច្រាក់ ដាវីដ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៣៥-លោកជំទាវ **ប៉ែន ច័ន្ទដាវី** មានឋានៈស្មើ អគ្គនាយក
៣៦-លោកជំទាវ **ព្រាប កែវច័ន្ទមុនី** មានឋានៈស្មើ អគ្គនាយក
៣៧-លោកជំទាវ **ហួត សុមាលី** មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

ចាវណ.-១៧០៩.៧០៤

លេខៈ ៦៥៩ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ[illegible] ឆ្នាំ២០១៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៩១៧/៦៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានៈដល់ឯកឧត្តម **ហ៊ុន ម៉ានិត** នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ២ : ដំឡើងឋានៈដល់ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២៨រូប ៖

១-ឯកឧត្តម **ឌី ពៅ**	មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម **យុន ហេង**	មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៣-ឯកឧត្តម **អ៊ុក ស៊ីដេន**	មានឋានៈស្មើ រដ្ឋលេខាធិការ
៤-ឯកឧត្តម **យឹម ម៉ិនឡុង**	មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៥-ឯកឧត្តម **ជួន ជីទិន**	មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៦-ឯកឧត្តម **ឡាក់ សោភ័ណ**	មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៧-ឯកឧត្តម **គោត សំអុន**	មានឋានៈស្មើ រដ្ឋលេខាធិការ
៨-ឯកឧត្តម **ទិន សុភា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៩-ឯកឧត្តម **ហាក់ ចាន់រឿន**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១០-ឯកឧត្តម **អ៊ុច ឌីណា**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១១-លោកជំទាវ **ឆេព សុទ្ធី**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១២-ឯកឧត្តម **ស្វាយ ដុត**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៣-ឯកឧត្តម **ឈន ម៉េងឡុង**	មានឋានៈស្មើ អនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១៤-ឯកឧត្តម **គីម រស្មី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៥-ឯកឧត្តម **ដួង តារា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
១៦-ឯកឧត្តម **សួង និតធានី** មានឋានៈស្មើ អគ្គនាយក
១៧-ឯកឧត្តម **ទឹម សុខ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
១៨-ឯកឧត្តម **សារិន វណ្ណា** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
១៩-ឯកឧត្តម **យស់ វណ្ណា** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២០-លោកជំទាវ **ឡាយ លក្ស្មី** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២១-ឯកឧត្តម **ឡុញ ម៉ារាល** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២២-លោកជំទាវ **កុច មារគី** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៣-ឯកឧត្តម **អនឃួន សំអូន** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៤-ឯកឧត្តម **ទ្រី ម៉ាន់ថា** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៥-ឯកឧត្តម **ច័ន្ទ ដារុណា** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៦-ឯកឧត្តម **ម៉ាន់ខែម ម៉ិនថន** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៧-ឯកឧត្តម **ណុប ចាន់ណារិទ្ធ** មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
២៨-ឯកឧត្តម **ឆាយ សុខហេង** មានឋានៈស្មើ អគ្គនាយក ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ចាស. ១៧០៩.៧០៥

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លេខ: ៧/០០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...១៥០...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា១ .-

ត្រូវបានកំណត់យកថ្ងៃទី១៥ ខែមិថុនា រៀងរាល់ឆ្នាំជា "**ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**" ដែលសរសេរជាអក្សរកាត់ថា "**ទ.ជ.អ.ប.វ**" ដើម្បីលើកកម្ពស់ការអប់រំ/...

បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងធ្វើការផ្សព្វផ្សាយ ទៅដល់សិស្សានុសិស្ស យុវជន មាតាបិតា អាណាព្យាបាល និងផ្នែកឯកជនឲ្យបានយល់ដឹងអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការជំរុញការអភិវឌ្ឍកម្លាំងពលកម្មជំនាញប្រកបដោយគុណភាព និងប្រសិទ្ធភាពឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅក្នុងនិងក្រៅប្រទេស។

មាត្រា២ .-

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំ **ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ** នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡានិងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សានានា អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល និងផ្នែកឯកជន។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់វិទ្យាស្ថានស៊ីអ៊ីអូ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា១.-

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានស៊ីអ៊ីអូ** សរសេរជាអក្សរកាត់ថា **វ.ស.អ.អ** និងជាភាសាអង់គ្លេសថា CEO Institute សរសេរជាអក្សរកាត់ថា CEO.I។

មាត្រា២.-

វិទ្យាស្ថានស៊ីអ៊ីអូ មានទីតាំងស្ថិតនៅ អគារលេខ២ ផ្លូវ៤៨៤ កែងផ្លូវ៩៧ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។ វិទ្យាស្ថានស៊ីអ៊ីអូ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

មាត្រា៣.-

វិទ្យាស្ថានស៊ីអ៊ីអូ ធ្វើការបណ្ដុះបណ្ដាល ដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិលើកម្រិតជំនាញដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ ឬ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត(សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

មាត្រា៤.-

វិទ្យាស្ថានស៊ីអ៊ីអូ ធ្វើការបណ្ដុះបណ្ដាលលើមុខជំនាញដូចខាងក្រោម៖

- អចលនទ្រព្យ
- ឥណទានធនាគារ
- ធានារ៉ាប់រង
- ពាណិជ្ជកម្មអន្តរជាតិ
- គណនេយ្យ និងហិរញ្ញវត្ថុ
- វិទ្យាសាស្ត្រនយោបាយ
- រចនាប្លង់ និងតុបតែង
- ភាសាបរទេស
- ផលិតផល និងសេវាកម្ម
- ផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ
- បដិសណ្ឋារកិច្ច និងគ្រប់គ្រងទេសចរណ៍
- ការគ្រប់គ្រងបណ្ដាញផ្គត់ផ្គង់ពាណិជ្ជកម្ម
- សរសេរកម្មវិធីកុំព្យូទ័រ និងរចនាគេហទំព័រ
- ច្បាប់
- ផលិតភាពយន្ត។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះ អាចបើកសាខា ប្ដូរទីតាំង ដេប៉ាតឺម៉ង់ថ្មី ឯកទេសថ្មី មហាវិទ្យាល័យ ដំឡើងកម្រិតឬថ្នាក់ថ្មី ប្រភេទបណ្ដុះបណ្ដាលថ្មី ឬបន្ថែមជំនាញផ្សេងៗទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

មាត្រា៥

វិទ្យាស្ថានស៊ីអ៊ីអូ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្ដែងនៃវិទ្យាស្ថានស៊ីអ៊ីអូ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

មាត្រា៦.-

នាយកវិទ្យាស្ថានស៊ីអ៊ីអូ មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានស៊ីអ៊ីអូ និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់-ធ្នាប់សង្គម
- ទទួលខុសត្រូវ ក្នុងការជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានទៀង-ទាត់តាមការកំណត់។

មាត្រា៧.-

សិក្ខាកាម សិស្ស និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយវិទ្យាស្ថានស៊ីអ៊ីអូ ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានស៊ីអ៊ីអូ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានឈ្មោះថា **ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល** សរសេរជាអក្សរកាត់ថា «ទ.ប.ច.ស.» ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស គឺក្រសួងសុខាភិបាល និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា២.-

ទ.ប.ច.ស. ជានីតិបុគ្គលនៃនីតិសាធារណៈមានថវិកាស្វយ័ត ដែលត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសុខាភិបាល។

ទ.ប.ច.ស. មានទីស្នាក់ការកណ្តាល ស្ថិតនៅក្នុងទីស្តីការក្រសួងសុខាភិបាល ដែលមានអាសយដ្ឋានដីឡូត៍លេខ៨០ វិថីសម្តេចប៉ែននុត(២៨៩) រាជធានីភ្នំពេញ។

មាត្រា៣ .-

ទ.ប.ច.ស. មានភារកិច្ចបញ្ជាក់ចំណាយមូលនិធិសមធម៌សេវាសុខាភិបាល និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល ដែលមានជាអាទិ៍ដូចតទៅ៖

- ពិនិត្យ និងបញ្ជាក់សំណើរបស់ភាគីផ្តល់សេវាក្នុងការទូទាត់ថ្លៃសេវាសុខភាព ដែលប្រើប្រាស់មូលនិធិសមធម៌សេវាសុខាភិបាល និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល
- អង្កេត តាមដាន វាយតម្លៃគុណភាពសេវាសុខភាពដែលប្រើប្រាស់មូលនិធិសមធម៌ និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល ដោយអនុលោមតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន

- អង្កេត តាមដាន និងវាយតម្លៃការប្រើប្រាស់មូលនិធិសមធម៌ និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាល និងហើយធ្វើការដោះស្រាយសមស្រប
- ផ្សព្វផ្សាយជូនសាធារណជនអំពីលទ្ធភាព និងលក្ខណៈវិនិច្ឆ័យក្នុងការផ្តល់ និងការទទួលបាននូវកញ្ចប់អត្ថប្រយោជន៍ថែទាំសុខភាព ស្របតាមយន្តការនៃការគ្រប់គ្រងមូលនិធិផ្តល់សេវាសុខាភិបាល របបមូលនិធិសមធម៌សុខាភិបាលដោយប្រើប្រាស់ឯកសារដែលមានការឯកភាពពីភាគីជាវសេវាសុខភាព និងស្ថាប័នមានសមត្ថកិច្ច
- រៀបចំ និងដាក់ឲ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាទាក់ទងនឹងការបើកផ្តល់ប្រាក់មូលនិធិផ្តល់សេវាសុខាភិបាល និងការទូទាត់ការបង់ថ្លៃសេវាសុខភាព របបមូលនិធិសមធម៌សុខាភិបាល។ ទិន្នន័យទូទាត់ការបង់ថ្លៃសេវាសុខាភិបាល ត្រូវផ្សារភ្ជាប់នឹងទិន្នន័យចុះបញ្ជីអ្នកប្រើប្រាស់សេវាសុខភាព និងទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- ផ្តល់យោបល់ជូនក្រសួងអាណាព្យាបាលទាំងពីរ និងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្រ និងនីតិវិធីទាក់ទងនឹងយន្តការគ្រប់គ្រងមូលនិធិផ្តល់សេវាសុខាភិបាល របបមូលនិធិសមធម៌សុខាភិបាល កំណត់កញ្ចប់អត្ថប្រយោជន៍ផ្នែកថែទាំសុខភាពសម្រាប់អ្នកប្រើប្រាស់ និយាមគុណភាពសេវាសុខាភិបាល តារាងតម្លៃសេវាសុខភាព និងលទ្ធភាពនៃការរួមចំណែកឧបត្ថម្ភថវិកាពីប្រភពដទៃទៀតក្រៅពីថវិកាជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៤.-

ម.ប.ច.ស. មានបេសកកម្មតាមដាន ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លើប្រតិបត្តិការ និងចំណាយមូលនិធិ-សមធម៌សុខាភិបាល និងមូលនិធិលើកកម្ពស់គុណភាពសេវាសុខាភិបាលរបស់ភាគីជាវសេវាសុខភាព ភាគីផ្តល់សេវាសុខភាព និងភាគីប្រើប្រាស់សេវាសុខភាព ដើម្បីធានាអនុលោមភាពគោលនយោបាយរបស់ក្រសួងសុខាភិបាលក្នុងការលើកកម្ពស់គុណភាព និងសមធម៌សេវាសុខាភិបាល។

ជំពូកទី២
ការដឹកនាំ និងការគ្រប់គ្រង
ផ្នែកទី១
ក្រុមប្រឹក្សាភិបាលរបស់ ម.ប.ច.ស.

មាត្រា៥.-

ម.ប.ច.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្មតម្រង់ទិសការអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងាររបស់គ្រឹះស្ថានក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មាត្រា៦.-

ម.ប.ច.ស. មានសមាជិកក្រុមប្រឹក្សាភិបាលចំនួន៧(ប្រាំពីរ)រូប ដែលមានសមាសភាពដូចតទៅ៖

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- តំណាងក្រសួងផែនការ សមាជិក
- តំណាងនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល សមាជិក
- តំណាងបុគ្គលិកនៃ **ទ.ប.ច.ស.** សមាជិកស្វ័យប្រវត្តិ។

ក្រុមប្រឹក្សាភិបាលនៃ **ទ.ប.ច.ស.** ត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ ០១ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត **ទ.ប.ច.ស.**។

មាត្រា៧.-

តំណាងបុគ្គលិកនៃ **ទ.ប.ច.ស.** ០១ រូប គឺជាសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិកសម្រាប់អាណត្តិ០៣ឆ្នាំ។ តំណាងបុគ្គលិកត្រូវក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោតដោយមិនចាំបាច់មានការតែងតាំងឡើយ។

តំណាងបុគ្គលិកនេះ ត្រូវបានជ្រើសរើសដោយការបោះឆ្នោត ដែលប្រព្រឹត្តទៅតាមលក្ខណៈប្រជាធិបតេយ្យ។ អ្នកមានសិទ្ធិបោះឆ្នោត សម្រាប់៖

ក. អាណត្តិដំបូងនៃក្រុមប្រឹក្សាភិបាល ជាបុគ្គលិកអចិន្ត្រៃយ៍ ។

ខ. អាណត្តិនៃក្រុមប្រឹក្សាភិបាលបន្តបន្ទាប់ទៀត ជាបុគ្គលិកទាំងអស់ដែលមានសិទ្ធិបោះឆ្នោតតាមការសម្រេចរបស់នាយកគ្រឹះស្ថាន។

តំណាងនេះ ត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ ដោយសម្លេងគាំទ្រភាគច្រើនដាច់ខាតស្របតាមលក្ខខណ្ឌវិនិច្ឆ័យ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ ហើយមានអាយុយ៉ាងតិច ២៥ ឆ្នាំ និងយ៉ាងច្រើន ៥៥ ឆ្នាំ
- បម្រើការងារយ៉ាងតិច ០៥ ឆ្នាំ ដោយយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍ឱ្យបុគ្គលិកទាំងអស់ និង **ទ.ប.ច.ស.**
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាព និងបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់តាមសំណូមពរ និងលក្ខខណ្ឌនៃការងាររបស់ **ទ.ប.ច.ស.**។

នីតិវិធីសម្រាប់ការបោះឆ្នោតតំណាងបុគ្គលិកជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិនីមួយៗនៃ **ទ.ប.ច.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយក **ទ.ប.ច.ស.**។

ក្រៅពីសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀតត្រូវមានអាណត្តិ ០៣ឆ្នាំ ដែលត្រូវបានតែងតាំង និងបញ្ចប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័ន ដែលមានសមាជិក

នោះតំណាងឱ្យ។ អាណត្តិនេះអាចបន្តសារជាថ្មីទៀតបានដោយអនុក្រឹត្យ ប៉ុន្តែមិនត្រូវលើសពី ០២ អាណត្តិឡើយ។

មាត្រា៨.-

បេក្ខភាពជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ឬឥស្សរជនដែលមានលក្ខណសម្បត្តិ និងបទពិសោធន៍ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- បម្រើការងារយ៉ាងតិច ០៥ ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាពជំនាញនៅក្នុងវិស័យពាក់ព័ន្ធ ជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។

មាត្រា៩.-

សមាជិកក្រុមប្រឹក្សាភិបាល អាចត្រូវបានបញ្ចប់មុនអាណត្តិតាមសំណើក្រសួង ស្ថាប័នតំណាងក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័ន តំណាងបុគ្គលិករបស់គ្រឹះស្ថានទទួលមរណៈភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

ក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួនរហូតដល់មានការតែងតាំងក្រុមប្រឹក្សា-ភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ត្រូវតែងតាំងយ៉ាងយូរបំផុត០១(មួយ)ខែ ក្រោយការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាលចាស់។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ក្រសួងសុខាភិបាលត្រូវរៀបចំសំណើទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិថ្មី។ ក្រសួងសុខាភិបាលត្រូវទទួលខុសត្រូវលើភាពយឺតយ៉ាវនៃការស្នើតែងតាំងក្រុមប្រឹក្សាភិបាល។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវមានបញ្ជាក់អំពីអាណត្តិដែលសមាជិកនោះត្រូវទទួល។

សមាជិកក្រុមប្រឹក្សាភិបាលថ្មី ដែលត្រូវតែងតាំងជំនួសកន្លែងទំនេរស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាល។

មុខងារជាប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល **ទ.ប.ច.ស.** មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល និងសមាជិកសភា។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាល **ទ.ប.ច.ស.** មានវិសមិតភាពជាមួយមុខងារជានាយកគ្រឹះស្ថាន។ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជាបន្ទុករបស់ **ទ.ប.ច.ស.** លើកលែងតែករណីដែលសមាជិកនោះ បានប្រព្រឹត្តកំហុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ។ សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទ-ល្មើសដែលខ្លួនបានប្រព្រឹត្ត។ សមាជិកក្រុមប្រឹក្សាភិបាល មានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញ ប្រកាន់

ខ្ជាប់នូវគោលជំហររាយការណ៍ជាប្រចាំពីសកម្មភាពការងារ ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនជូនក្រសួង ស្ថាប័នដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.ប.ច.ស.**។

មាត្រា១០.-

សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប នឹងទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមគោលការណ៍កំណត់ជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកក្រុមប្រឹក្សាភិបាលនៃ **ទ.ប.ច.ស.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរ-ញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ អាចត្រូវបានផ្អាកដោយក្រសួង ស្ថាប័ន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ពុំគោរពអាណត្តិកិច្ចរបស់ខ្លួន ដែលមានជាអាទិ៍គឺ៖

១- ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងមនសិការវិជ្ជាជីវៈ

២- ការគោរពបទបញ្ជា និងបទប្បញ្ញត្តិរបស់ **ទ.ប.ច.ស.**

៣- ការបំពេញតួនាទី និងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល

៤-ការអនុវត្តកាតព្វកិច្ចរាយការណ៍ ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័នដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ។

ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើវិស័យពាក់ព័ន្ធជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍន៍ឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

មាត្រា១១.-

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសកម្មភាពការងារ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ទ.ប.ច.ស.**។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍របស់គ្រឹះស្ថានទាំងសម្រាប់រយៈពេលមធ្យម ទាំងសម្រាប់រយៈពេលវែង
- ពិនិត្យ និងអនុម័តគម្រោងថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ **ទ.ប.ច.ស.**
- ពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រង **ទ.ប.ច.ស.** របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះ **ទ.ប.ច.ស.**
- ជំរុញដំណើរការរបស់គណៈកម្មាធិការ និងគណៈកម្មការ ដែលបង្កើតឡើងដោយអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថាន ព្រមទាំងបង្កើតគណៈកម្មាធិការ និងគណៈកម្មការនានាតាមការចាំបាច់
- កំណត់នូវនីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឬការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- ពិនិត្យនិងអនុម័តលើសំណើសុំកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់នាយកគ្រឹះស្ថាន
- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត។

មាត្រា១២.-

យ៉ាងយូរ០១ខែ ក្រោយការបង្កើតក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូងដែលរបៀបវារៈសំខាន់ គឺការរៀបចំសេចក្តីព្រាងប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ **ទ.ប.ច.ស.** ដែលក្នុងនោះត្រូវបញ្ជាក់ពីរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះ **ទ.ប.ច.ស.**។

ក្រុមប្រឹក្សាភិបាលនៃ **ទ.ប.ច.ស.** មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញតាមគំនិតផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២ភាគ៣ ឬពីនាយក **ទ.ប.ច.ស.** តាមការចាំបាច់។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងការអនុវត្តថវិកា ការពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ។

នាយកគ្រឹះស្ថាន ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសមន្ត្រីម្នាក់ជាលេខាធិការនៃអង្គប្រជុំ។ នាយក **ទ.ប.ច.ស.** និងលេខាធិការនេះ ពុំមានសិទ្ធិបោះឆ្នោតទេ។

ក្រុមប្រឹក្សាភិបាលធ្វើការលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០ ថ្ងៃ នៃថ្ងៃធ្វើការងារដល់គ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា ៣៦ នៃអនុក្រឹត្យនេះ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែពុំមានសិទ្ធិបោះឆ្នោត។

ការប្រជុំក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី ៥០ ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមាន ពុំអាចឱ្យគេជំនួសបានឡើយ។

ប្រសិនបើកូរ៉ុមពុំបានគ្រប់គ្រាន់ នោះប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មី ក្នុងរយៈពេល ១៥ ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី ១ ប៉ុណ្ណោះ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងរក្សាទុកនៅទីស្នាក់ការរបស់ **ទ.ប.ច.ស.** ដោយមានចុះហត្ថលេខារបស់ប្រធាន។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុនេះត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវរៀបចំ និងផ្ញើសេចក្តីព្រាងកំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល ០២ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល ០៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំ ដើម្បី

បញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលចុះហត្ថលេខាលើកំណត់ហេតុ ដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាលនិងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើ ត្រូវបញ្ជូនក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ។

ការប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំត្រូវធ្វើឡើងជាចាំបាច់ ដោយមិនត្រូវឆ្លងខែបន្ទាប់នៃដំណាច់ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ គឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

ផ្នែកទី២
អង្គភាពប្រតិបត្តិរបស់ ទ.ប.ច.ស.

មាត្រា១៣.-

ទ.ប.ច.ស. ត្រូវគ្រប់គ្រងដោយនាយក០១(មួយ)រូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយក ទ.ប.ច.ស. មានតួនាទីជានាយកប្រតិបត្តិ។ ការតែងតាំងនាយកត្រូវធ្វើឡើងយ៉ាងយូរ ០១(មួយ)ខែ ក្រោយពីការចូលជាធរមាននៃអនុក្រឹត្យនេះ។

មុខងារជានាយកគ្រឹះស្ថាន មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល ឬសមាជិកសភា និងសមាជិកក្រុមប្រឹក្សាភិបាល។

យ៉ាងយូរ០១(មួយ) ខែ ក្រោយការតែងតាំងនាយក ទ.ប.ច.ស. ត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។

មាត្រា១៤.-

នាយកគ្រឹះស្ថាន ជាតំណាងរបស់គ្រឹះស្ថាន ក្នុងការទំនាក់ទំនងជាមួយតតិយជន។ នាយកគ្រឹះស្ថានបំពេញមុខងារ និងភារកិច្ច ដូចតទៅ៖

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍គ្រឹះស្ថាន ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង អនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថាន ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រងគ្រឹះស្ថាន របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត

- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់របស់គ្រឹះស្ថាន
- បញ្ជូនបញ្ជីសារពើភណ្ឌទាំងនោះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យ តាមដាន ព្រមទាំងរាយការណ៍ ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ ក្នុងករណីចាំបាច់ នូវភារកិច្ចដែលត្រូវបានប្រគល់ជូនអង្គភាពចំណុះនានានៃគ្រឹះស្ថាន
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនមន្ត្រីរាជការ និងបុគ្គលិករបស់គ្រឹះស្ថានជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ សម្រាប់បុគ្គលិកគ្រប់ប្រភេទជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយដទៃទៀត ដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ទ.ប.ច.ស.** មានសិទ្ធិស្នើទៅក្រសួងសុខាភិបាល សុំតែងតាំងនាយករង០១(មួយ)រូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់។ នាយករង ត្រូវមានចំណេះដឹងលើផ្នែកបច្ចេកទេសតាមវិស័យនីមួយៗ ដែលត្រូវទទួលគ្រប់គ្រង។

ផ្នែកទី៣
បុគ្គលិករបស់ ទ.ប.ច.ស.

មាត្រា១៥.-

បុគ្គលិកអចិន្ត្រៃយ៍របស់ **ទ.ប.ច.ស.** គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារក្នុង **ទ.ប.ច.ស.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទ.ប.ច.ស. អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិករបស់ **ទ.ប.ច.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្ដីពីបុគ្គលិក ត្រូវអនុលោមតាមបទប្បញ្ញត្តិ ទាំងឡាយនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត របស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបំពេញភារកិច្ចនៅ **ទ.ប.ច.ស.** ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ពីថវិការដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗក្រៅពីថវិការដ្ឋជូនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកជាប់កិច្ចសន្យានៃ **ទ.ប.ច.ស.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់នាយកគ្រឹះស្ថាន បន្ទាប់ពីមានការយល់ព្រមពីក្រុម-ប្រឹក្សាភិបាល។

ផ្នែកទី៤
ទ្រព្យសម្បត្តិ ទ.ប.ច.ស.

មាត្រា១៦.-

ទ.ប.ច.ស. ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ទ.ប.ច.ស. មានទ្រព្យសម្បត្តិ ដែលរួមមាន៖

ក- ធនធានគ្រាដំបូងទទួលបានពីរដ្ឋ ដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យបង្កើតគ្រឹះស្ថាននេះ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មាធិការអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាពពីអាណាព្យាបាលទាំងពីរ។ តារាងតុល្យការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា។

ខ-ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដែលអាចរកបានក្រោយថ្ងៃបង្កើត **ទ.ប.ច.ស.** ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ទ.ប.ច.ស. ត្រូវបង្កើតគណៈកម្មការមួយ មានឈ្មោះថា គណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថាន។ នាយកគ្រឹះស្ថានដែលជាប្រធាន និងសមាជិកដទៃទៀតនៃគណៈកម្មការនេះ ត្រូវទទួលខុសត្រូវ និងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌដែលបានរៀបចំរួច។ ការរៀបចំបញ្ជីសារពើភណ្ឌ ត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយដោយអនុលោមទៅតាមបែបបទនីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ទ.ប.ច.ស. មានកាតព្វកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង និងថយចុះប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវ ដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចហើយត្រូវផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋយ៉ាងយូរនៅចុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។

ទ.ប.ច.ស. អាចធ្វើការទិញ-លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យ លុះត្រាតែទ្រព្យសម្បត្តិទាំងនោះ ត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌ និងនីតិវិធីនៃការទិញ-លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ ហើយត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែល **ទ.ប.ច.ស.** ត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយអនុក្រឹត្យទ្រព្យសកម្មដែលជាចលនទ្រព្យ និងអចលនទ្រព្យរបស់ **ទ.ប.ច.ស.** ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ

ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុត្រូវបង្វិលចូលគណនីទោលរបស់រតនាគារជាតិ។

ផ្នែកទី៥
ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ទ.ប.ច.ស.

មាត្រា១៧.–

ទ.ប.ច.ស. ត្រូវមានគណនេយ្យភាពចំពោះក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

មាត្រា១៨.–

នាយកគ្រឹះស្ថានជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់ **ទ.ប.ច.ស.** ដែលទទួលបានការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលជាអាណាប័កដើមខ្សែដោយមានសិទ្ធិអំណាច ដូចតទៅ៖

- បញ្ជា និងជម្រះចំណូល
- បញ្ជាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ នាយកគ្រឹះស្ថានអាចផ្ទេរសិទ្ធិនេះបន្តឱ្យអាណាប័កជំនួស ដោយមានការយល់ព្រមពីអាណាប័កដើមខ្សែ។

ក្រសួងសុខាភិបាលត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថាន តាមសំណើរបស់នាយកគ្រឹះស្ថាន និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅ**ទ.ប.ច.ស.**។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ០៣ ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការបង្កើតរដ្ឋទេយ្យចំណូល និង/ឬ រដ្ឋទេយ្យបុរេប្រទាន ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល បន្ទាប់ពីទទួលបានសំណើពីនាយកគ្រឹះស្ថាន និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។

ការតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករបុរេប្រទាន ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល បន្ទាប់ពីទទួលបានសំណើពីនាយកគ្រឹះស្ថាន និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល។

មាត្រា១៩.–

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់បញ្ជីគណនេយ្យ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។

គណនេយ្យករត្រូវមានគុណវុឌ្ឍិ ព្រមទាំងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ គ្រប់គ្រាន់ និងបំពេញលក្ខខណ្ឌផ្សេងទៀត ដែលស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណនេយ្យករ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណនេយ្យករ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់។

គណនេយ្យករ មានភារកិច្ចៈ

- គ្រប់គ្រងការប្រមូលចំណូល
- ទូទាត់ចំណាយ
- រក្សាទុក និងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់គ្រឹះស្ថាន។

គណនេយ្យករ អាចមានមន្ត្រីជំនាញមួយចំនួនជាជំនួយការក្នុងការបំពេញមុខងាររបស់ខ្លួន។

មាត្រា២០.-

ប្រភពធនធានរបស់ **ទ.ប.ច.ស.** រួមមានៈ

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ទ.ប.ច.ស.** នៅពេលចាប់ផ្តើមបង្កើតដំបូងស្របតាមមាត្រា ១៦ នៃអនុក្រឹត្យនេះ
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានគ្រោងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន
- អំណោយ ជំនួយ និងអច្ច័យទានដែល **ទ.ប.ច.ស.** បានទទួល
- កម្រៃសេវាសាធារណៈ ឬភាគទានដែល **ទ.ប.ច.ស.** មានសិទ្ធិប្រមូល ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- កម្រៃពីទ្រព្យសម្បត្តិរបស់ **ទ.ប.ច.ស.** និងចំណូលពីការលក់ទ្រព្យសម្បត្តិទាំងនោះស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា២១.-

ចំណូល ចំណាយចរន្ត និងមូលធនរបស់ **ទ.ប.ច.ស.** ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ **ទ.ប.ច.ស.** និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិកាក្រសួងសុខាភិបាល។

ចំណូលរបស់ **ទ.ប.ច.ស.** រួមមានការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗស្របតាមមាត្រា២០។

ថវិកាត្រូវរៀបចំដោយនាយក **ទ.ប.ច.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងសុខាភិបាលពិនិត្យនិងសម្រេច មុននឹងបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ថវិកា ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ។

លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈរបស់ **ទ.ប.ច.ស.** គឺជាបន្ទុកនៃថវិការដ្ឋ។

ចំណូល និងចំណាយរបស់ **ទ.ប.ច.ស.** ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិការដ្ឋដែរ។

ចំណាយ ត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

ទ.ប.ច.ស. មិនអាចបង្កើតលក្ខខណ្ឌដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា២២.-

គណនេយ្យរបស់ **ទ.ប.ច.ស.** រួមមាន៖

- គណនេយ្យទូទៅដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

កិច្ចបញ្ជិកាគណនេយ្យរបស់ **ទ.ប.ច.ស.** ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គណនេយ្យករ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ដាក់ជូននាយកគ្រឹះស្ថាន និងក្រុមប្រឹក្សាភិបាល។

របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស ត្រូវដាក់ជូននាយកគ្រឹះស្ថានដើម្បីពិនិត្យនិងយល់ព្រម និងត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាលដើម្បីប្រជុំពិនិត្យ និងអនុម័តយ៉ាងយូរ ១០ ថ្ងៃ ក្រោយពីដំណាច់ត្រីមាស និងឆមាសនីមួយៗ និងចម្លងជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវដាក់ជូននាយកគ្រឹះស្ថានពិនិត្យ និងយល់ព្រម និងបញ្ជូនទៅក្រុម-ប្រឹក្សាភិបាលពិនិត្យ និងអនុម័តយ៉ាងយូរ ០៣ ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។ របាយការណ៍នេះ ត្រូវបានបញ្ជូនជាបន្តបន្ទាប់ជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មាត្រា២៣.-

ថវិការបស់**ទ.ប.ច.ស.** គឺជាមូលនិធិសាធារណៈ របស់រដ្ឋ ដែលត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អតិរេករបស់ **ទ.ប.ច.ស.** ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ អតិរេកនេះ ត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អតិរេកនេះ អាចត្រូវបានចាត់ចែង សម្រាប់ការវិនិយោគជាប្រយោជន៍ដល់ការអភិវឌ្ឍ **ទ.ប.ច.ស.** ឬជាកម្មវត្ថុនៃការបង់ចូលថវិកាជាតិ។ ការចាត់ចែងអតិរេកនេះ ត្រូវមានការយល់ព្រមពីក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី៦
របបសារពើពន្ធរបស់ ទ.ប.ច.ស.

មាត្រា២៤.-

ទ.ប.ច.ស. ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់។

ផ្នែកទី ៧
ការទារលទ្ធកម្មរបស់ ទ.ប.ច.ស.

មាត្រា២៥.-

ការគ្រប់គ្រង ការអនុវត្តនិងការត្រួតពិនិត្យការងារលទ្ធកម្មក្នុង **ទ.ប.ច.ស.** ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ជំពូកទី៣
អាណាព្យាបាលភាព

មាត្រា២៦.-

ទ.ប.ច.ស. មានអាណាព្យាបាលពីរ ដូចខាងក្រោម៖

១- អាណាព្យាបាលបច្ចេកទេស គឺក្រសួងសុខាភិបាល។

២- អាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានថវិកា ជាសេនាធិការក្នុងការសម្របសម្រួលគ្រប់គ្រង **ទ.ប.ច.ស.**។

មាត្រា២៧.-

អាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ អាចចាត់មន្ត្រីមានសមត្ថកិច្ចឱ្យធ្វើអធិការកិច្ច សវនកម្ម តាមដាន និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការនានារបស់ **ទ.ប.ច.ស.** តាមការចាំបាច់។

មាត្រា២៨.-

ទ.ប.ច.ស. ត្រូវផ្តល់ជូនអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ក្រោយការពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាល នូវឯកសារដូចខាងក្រោម៖

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍ **ទ.ប.ច.ស.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ប.ច.ស.**
- របាយការណ៍គ្រប់គ្រង **ទ.ប.ច.ស.** របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុ។

ទទួលបានឯកសារខាងលើ អាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន ត្រូវចាត់ការបន្តតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន។

ផ្នែកទី១

អាណាព្យាបាលបច្ចេកទេស

មាត្រា២៩.-

អាណាព្យាបាលបច្ចេកទេសមានភារកិច្ច ដូចខាងក្រោម៖

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ **ទ.ប.ច.ស.** អនុវត្ត
- ពិនិត្យ និងសម្រេចផែនការអភិវឌ្ឍន៍របស់ **ទ.ប.ច.ស.**
- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងនៃគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ប.ច.ស.**
- ពិនិត្យ និងសម្រេចលើសំណើចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ
- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់ **ទ.ប.ច.ស.**
- ដាក់ចេញនូវវិធានការកែលម្អនានាពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់ **ទ.ប.ច.ស.**
- ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធនៃ **ទ.ប.ច.ស.**
- ស្នើតែងតាំងនាយក **ទ.ប.ច.ស.**
- តែងតាំងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅ **ទ.ប.ច.ស.** អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

មាត្រា៣០.-

អនុលោមតាមបទប្បញ្ញត្តិជាធរមាន អាណាព្យាបាលបច្ចេកទេស ត្រូវផ្ញើជូនអាណាព្យាបាលហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរនូវការសម្រេចទាំងឡាយរបស់ខ្លួន និងរបស់ក្រុមប្រឹក្សាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យ និងសម្រេចមានជាអាទិ៍៖

- ផែនការអភិវឌ្ឍន៍ **ទ.ប.ច.ស.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ប.ច.ស.**
- ការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សេចក្តីសម្រេចស្តីពីការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- សេចក្តីសម្រេចផ្សេងទៀត ដែលអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

មាត្រា៣១.-

ក្រសួងសុខាភិបាលមានសិទ្ធិលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹង **ទ.ប.ច.ស.** ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកគ្រឹះស្ថាន ផ្ទុយនឹងគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់ **ទ.ប.ច.ស.** ក៏ដូចជារបស់ក្រសួងសុខាភិបាល

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកគ្រឹះស្ថាន ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សេចក្តីសម្រេចធ្វើឡើងដោយក្រសួង ស្ថាប័ន អាជ្ញាធរដែលមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬសេចក្តីសម្រេចធ្វើឡើងដោយការប្រជុំក្រុមប្រឹក្សាភិបាលដែលពុំអនុលោមតាមនីតិវិធី
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកខាងលើនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសុខាភិបាល ដោយមានបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ក្រសួងសុខាភិបាល ត្រូវជូនដំណឹងអំពីប្រកាសនេះ ដល់នាយកគ្រឹះស្ថាន។ នាយកគ្រឹះស្ថានត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

មាត្រា៣២.-

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល ឬនាយកគ្រឹះស្ថានពុំប្រតិបត្តិតាមបណ្តាវិធានដែលមានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.ប.ច.ស.** ក្រសួងសុខាភិបាលអាចចាត់ចែងការងារចេញសេចក្តីសម្រេច និងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក។

ផ្នែកទី២
អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា៣៣.-

អាណាព្យាបាលហិរញ្ញវត្ថុ មានភារកិច្ចៈ

- ពិនិត្យ និងផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍ **ទ.ប.ច.ស.**
- ពិនិត្យ និងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ **ទ.ប.ច.ស.**
- ពិនិត្យ និងអនុម័តផែនការលទ្ធកម្មរបស់ **ទ.ប.ច.ស.**
- ពិនិត្យ និងសម្រេចលើការចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- ពិនិត្យ និងផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យ និងសម្រេចលើសេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យ និងសម្រេច ឬផ្តល់ការយល់ព្រមលើឯកសារផ្សេងៗទៀត តាមសំណើរបស់ក្រសួងសុខាភិបាលស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំ និងដាក់ឱ្យអនុវត្តនូវវិធាននិងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និងបទដ្ឋានគតិយុត្តទាំងឡាយដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

មាត្រា៣៤.-

សេចក្តីសម្រេចរបស់នាយកគ្រឹះស្ថាន ក្រុមប្រឹក្សាភិបាល និងរបស់អាណាព្យាបាលបច្ចេកទេស ដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុដូចមានចែងក្នុងមាត្រា៣៣ នៃអនុក្រឹត្យនេះពុំមានអានុភាពអនុវត្តឡើយ ក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងនាយក **ទ.ប.ច.ស.** នូវការជំទាស់របស់ខ្លួនដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់។ នាយក និងក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យ និងដោះស្រាយឱ្យបានឆាប់បំផុត នូវករណីដែលបានលើកឡើងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មាត្រា៣៥.-

អាណាព្យាបាលហិរញ្ញវត្ថុ អាចលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុរបស់នាយកគ្រឹះស្ថាន ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់នាយកគ្រឹះស្ថាន ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេសផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោល ឬការផ្អាកទុកនេះ ត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងដល់អាណាព្យាបាលបច្ចេកទេស និងនាយកគ្រឹះស្ថាន ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត។

មាត្រា៣៦.-

អាណាព្យាបាលហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ០១(មួយ)រូប ប្រចាំ **ទ.ប.ច.ស.** ដើម្បីបំពេញមុខងារដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន។

ជំពូកទី៤
ការត្រួតពិនិត្យ

មាត្រា៣៧.-

ទ.ប.ច.ស. ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេសតាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

មាត្រា៣៨.-

ទ.ប.ច.ស. ត្រូវស្ថិតនៅក្រោមការធ្វើអធិការកិច្ចសវនកម្ម តាមដាន ត្រួតពិនិត្យដោយអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិស្របតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ **ទ.ប.ច.ស.** អាចត្រូវបានតម្រូវឱ្យស្ថិតក្រោមការធ្វើសវនកម្ម ដោយសវនករឯករាជ្យ ដោយមានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា៣៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៤៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ផ្ទេរក្របខ័ណ្ឌលោក **លី គីមសួ** ពីឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ មកឋានន្តរសក្តិ **វរសេនីយ៍ឯក** អត្តលេខ ៧៨៦៥២ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- -ដូចមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:..១០៤៧..អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងមន្រ្តីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០២ រូប នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដូចមានរាយនាមខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ឯក **លឹម ឡុង** អត្តលេខ ០៩៦៥ ប្រធាននាយកដ្ឋានសវនកម្មទី១ ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

២- លោកឧត្តមសេនីយ៍ទោ **សាន ស៊ីណា** អត្តលេខ ៦៨៦៨៩ អនុប្រធាននាយកដ្ឋាន ទៅជាប្រធាននាយកដ្ឋានសវនកម្មទី១ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៤៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១.- តែងតាំង លោក **ម៉ម ឆវីរៈ** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ ជំនួសលោក **ហួយ សិទ្ធិគុណ** ដែលបានចូលនិវត្តន៍។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០៤៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់មុខតំណែង តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .- បញ្ចប់មុខតំណែង តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៥ នាក់ នៅអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចខាងក្រោម ៖

១-បញ្ចប់មុខតំណែងលោក **ឡុង វណ្ណា** ពីប្រធានផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ ដោយត្រូវផ្ទេរទៅអង្គភាពដើមវិញ

២-បញ្ចប់មុខតំណែងលោក **លឹម ប៉ូ** ពីប្រធានផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា ដោយត្រូវផ្ទេរទៅអង្គភាពដើមវិញ

៣-តែងតាំងលោក **មាន តារារិទ្ធិ** ជាប្រធានផ្នែករដ្ឋបាល បុគ្គលិក ផែនការ និងហិរញ្ញវត្ថុ ជំនួសលោក ឡុង វណ្ណា ដែលបានបញ្ចប់មុខតំណែង

៤-តែងតាំងលោក **ស៊ីន សុជាតិ** ជាប្រធានទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ ជំនួសលោក សុខ ស៊ីចាន់ ដែលបានចូលនិវត្តន៍

៥-ប្រគល់ភារកិច្ចលោកស្រី **ឃិន រស្មី** ឱ្យបំពេញមុខងារជាប្រធានផ្នែកផ្សព្វផ្សាយ និងព័ត៌មានវិទ្យា ជំនួសលោក លឹមប៉ូ ដែលបានបញ្ចប់មុខតំណែង ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០៥០.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការធ្វើនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .- និយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់ តាមអតីតភាពការងារ ដល់មន្ត្រីរាជការចំនួន ០៣ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងចំនួន ០២ ដូចមានរាយនាមខាងក្រោម ៖

ក/-ក្រសួងធម្មការ និងសាសនា

១- លោក **វណ្ណា ប៊ុនណារ៉ា** ពីអនុមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ២

ខ/-ក្រសួងមុខងារសាធារណៈ

១- លោក **ធន់ ប៊ុនធឿន** ពីអនុមន្ត្រី ថ្នាក់លេខ ៤ មកវរមន្ត្រី ថ្នាក់លេខ ៤

២- លោក **សូ ម៉ាង** ពីអនុមន្ត្រី ថ្នាក់លេខ ៣ មកវរមន្ត្រី ថ្នាក់លេខ ៣

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៤១...អនក្រ.គត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ឥស្សរិយយស** ជូនមន្ត្រីរាជការ ចំនួន៤រូប ដែលបានខិតខំបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងបានចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យអប់រំ នៅសាលាចំណេះទូទៅអនុវិទ្យាល័យបូស្តទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

១-លោក	ជា ជាតិ	ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ
២-លោក	អ៊ុក សម្បត្តិ	ប្រធានការិយាល័យផែនការ នៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ
៣-លោក	ឆេត ទិសុទ្ធ	អនុប្រធានការិយាល័យផែនការ នៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ
៤-លោក	ម៉ែន សុទ្ធី	អនុប្រធានការិយាល័យផែនការ នៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១. បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន៥រូប ដែលបានជួយឧបត្ថម្ភថវិកាដល់គ្រូបង្រៀន បុគ្គលិក និងការស្នាក់នៅរបស់សិស្ស នៅមជ្ឈមណ្ឌលកុមារកំព្រាច្រករមៀត ស្ថិតនៅឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-DR. AHMED SALEH A.ALSUDAIS សប្បុរសជនរស់នៅប្រទេសអារ៉ាប៊ីសាអូឌីត ថវិកាចំនួន ១៦.០០០ ដុល្លារ

២-SHEIKH /IBRAHIM ABDULAZIZ A.ALKADEERI សប្បុរសជនរស់នៅប្រទេសអារ៉ាប៊ីសាអូឌីត ថវិកាចំនួន ១២.០០០ ដុល្លារ

៣-SHEIKH /ABDULMAJED ABDULAZIZ A.ALBESHR សប្បុរសជនរស់នៅប្រទេសអារ៉ាប៊ីសាអូឌីត ថវិកាចំនួន ១១.០០០ ដុល្លារ

៤-SHEIKH /FAHAD ZAID A.ALSABR សប្បុរសជនរស់នៅប្រទេសអារ៉ាប៊ីសាអូឌីត ថវិកាចំនួន ១០.៦០៨ ដុល្លារ

៥-MR SALAH EDDINE CHAAOUR សប្បុរសជនរស់នៅប្រទេសអារ៉ាប៊ីសាអូឌីត ថវិកាចំនួន ១០.៣២០ ដុល្លារ

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ៦៦គ្រឿង ជូនមន្ត្រីរាជការ ចំនួន ៦៦រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិ មាតុភូមិកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

ក-មេដាយមាសការងារ

១-	លោក	**យ៉ែម វណ្ណៈ**	ប្រធានការិយាល័យធម្មការ និងសាសនាស្រុកអូរជ្រៅ
២-	លោកស្រី	**យិន គីមយាង**	អនុប្រធានការិយាល័យរដ្ឋបាល
៣-	លោក	**មាស វ៉ាត**	មន្ត្រីការិយាល័យរដ្ឋបាល
៤-	លោក	**ថន សុធា**	នាយកពុទ្ធិកវិទ្យាល័យ សម្តេច ជួន ណាត
៥-	លោក	**ថោង រួម**	មន្ត្រីការិយាល័យធម្មការ និងសាសនាស្រុកមង្គលបុរី
៦-	លោក	**សេង គីមយ៉េង**	ប្រធានសមាគមអាចារ្យខ្មែរស្រុកមង្គលបុរី
៧-	លោក	**ឆេស សឿន**	មន្ត្រីមន្ទីរធម្មការ និងសាសនាខេត្តបន្ទាយមានជ័យ
៨-	លោក	**នួន សឿន**	មេឃុំស្វាយប្រទាល
៩-	វរសេនីយ៍ត្រី	**ឆាប កុសល**	អត្តលេខ ៣១៧៦២
១០-	អនុសេនីយ៍ឯក	**ដួង នីរិទ្ធី**	អត្តលេខ ៣១៧៦២
១១-	អនុសេនីយ៍ឯក	**ង៉ែត សុធារិទ្ធ**	អត្តលេខ ៦៦៥៨៩
១២-	វរសេនីយ៍ទោ	**ពក វាសនា**	អត្តលេខ ០៧០៥៣
១៣-	អនុសេនីយ៍ទោ	**វណ្ណៈ ឆវ៉ា**	អត្តលេខ ៦៦៥៨៩

១៤-	អនុសេនីយ៍ឯក	ចេង ស៊ីវុទ្ធី	អត្តលេខ ៣២១២៤
១៥-	អនុសេនីយ៍ឯក	ភា សាគី	អត្តលេខ ៦៧៦៣៧
១៦-	វរសេនីយ៍ឯក	ឆាង កុសល	អត្តលេខ ៣១៧៦២

ខ-មេដាយប្រាក់ការងារ

១-	លោក	បៀច ថាន	មន្ត្រីការិយាល័យពុទ្ធិកសិក្សា និងបណ្ណាល័យ
២-	លោក	ព្រហ្ម សខួន	មន្ត្រីការិយាល័យពុទ្ធសាសនាផ្សារភ្ជាប់សង្គម
៣-	លោក	ម៉ៅ សុផល	មន្ត្រីការិយាល័យពុទ្ធសាសនាផ្សារភ្ជាប់សង្គម
៤-	លោក	ឡាយ ស្រួច	ប្រធានការិយាល័យគណនេយ្យ
៥-	លោក	យិន គីមយី	មន្ត្រីការិយាល័យពាហិរសាសនា
៦-	លោក	ឱគួង សម្ផស្ស	មន្ត្រីការិយាល័យពុទ្ធសាសនាផ្សារភ្ជាប់សង្គម
៧-	លោក	គីម ម៉ៃ	មន្ត្រីការិយាល័យពុទ្ធិកសិក្សា និងបណ្ណាល័យ
៨-	លោកស្រី	ឃិន សុគារី	មន្ត្រីការិយាល័យរដ្ឋបាល
៩-	លោកស្រី	ឃ្លាំង ចិន្តា	មន្ត្រីការិយាល័យពុទ្ធិកសិក្សា និងបណ្ណាល័យ
១០-	លោក	លេង រុងរឿង	នាយកពុទ្ធិកវិទ្យាល័យសម្តេច ជា ស៊ីម
១១-	លោក	ទ៉ាង ឡុង	ប្រធានការិយាល័យធម្មការ និងសាសនាស្រុកម៉ាឡៃ
១២-	លោក	ប៊ុក សំអាង	មន្ត្រីកាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
១៣-	លោក	កង លាងគិន	មន្ត្រីកាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
១៤-	លោក	ភាន សារី	មន្ត្រីកាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
១៥-	អនុសេនីយ៍ទោ	ស៊ឹម សារិន	អត្តលេខ ៦៩២០៦

គ-មេដាយសំរិទ្ធការងារ

១-	ព្រះវិជយានុវ័ត្ត	ណាប់ ម៉ឺន	ព្រះបាឡាត់គណខេត្តបន្ទាយមានជ័យ
២-	ព្រះបរវិជ្ជា	ស៊ឹម សារ៉ាន	ព្រះសាកលវិទ្យាធិការរង ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
៤-	ព្រះឥន្ទបញ្ញោ	យី យ៉ុន	ព្រះសមុហ៍ធរគណខេត្តបន្ទាយមានជ័យ
៥-	ព្រះសោភ័ណវិបល	ម៉ាត សុគន្ធ	ព្រះអនុគណក្រុងសេរីសោភ័ណ
៦-	ព្រះបច្ចឹមសីមាវាសី	ប៊ុក ចំរើន	ព្រះអនុគណក្រុងប៉ោយប៉ែត
៧-	ព្រះចន្ទបញ្ញោ	អ៊ូ សុផល	ព្រះវិន័យធរអនុគណក្រុងសេរីសោភ័ណ
៨-	ព្រះធម្មោវាទី	ម៉ៅ សុផល	ព្រះធម្មធរអនុគណក្រុងសេរីសោភ័ណ
៩-	ព្រះសារទោ	អឿម វណ្ណា	ព្រះសមុហ៍អនុគណក្រុងសេរីសោភ័ណ
១០-	ព្រះសារទោ	អ៊ួង ច័ន្ទឧត្តម	ព្រះលេខាអនុគណក្រុងសេរីសោភ័ណ
១១-	ព្រះមហា	ម៉ាក់ ម៉េង	នាយកពុទ្ធិកវិទ្យាល័យ វត្តសុវណ្ណគីរី
១២-	ព្រះមហា	ឆួច សុខណា	គ្រូបង្រៀនពុទ្ធិកវិទ្យាល័យ សម្តេច ជួន ណាត
១៣-	លោក	គ្រុត សុខជា	ប្រធានការិយាល័យពាហិរសាសនា
១៤-	លោក	ឆួច ចាន់ណា	អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
១៥-	លោក	ជេន មាស	គ្រូបង្រៀនពុទ្ធិកវិទ្យាល័យ សម្តេច ជួន ណាត
១៦-	លោក	ធិ សារិយៈវង្ស	គ្រូបង្រៀនពុទ្ធិកបឋមសិក្សា ក្រុងកំពង់ចាម
១៧-	លោកស្រី	ម៉ៅ ភាម៉ិច	មន្ត្រីមន្ទីរធម្មការ និងសាសនាខេត្តបន្ទាយមានជ័យ

១៨-	លោកស្រី	ផល សុម៉ាលី	គ្រូពុទ្ធិកបឋមសិក្សាខខេត្តបន្ទាយមានជ័យ
១៩-	លោក	សួន សិរី	គ្រូពុទ្ធិកបឋមសិក្សាខេត្តបន្ទាយមានជ័យ
២០-	លោក	សេង ចន្ថា	គ្រូពុទ្ធិកបឋមសិក្សាខេត្តបន្ទាយមានជ័យ
២១-	លោក	តឹក ទីរ៉ា	គ្រូពុទ្ធិកបឋមសិក្សាខេត្តបន្ទាយមានជ័យ
២២-	លោក	រ៉ាន់ រ៉ាយូ	គ្រូពុទ្ធិកបឋមសិក្សាខេត្តបន្ទាយមានជ័យ
២៣-	លោក	ចាន់ ឌីន	គ្រូពុទ្ធិកបឋមសិក្សាខេត្តបន្ទាយមានជ័យ
២៤-	លោក	សង់ សារឿន	គ្រូពុទ្ធិកបឋមសិក្សាខេត្តបន្ទាយមានជ័យ
២៥-	លោកស្រី	សែត សុពិសី	មន្ត្រីការិយាល័យពាហិរសាសនា
២៦-	លោក	សេក ផាំនេត	មន្ត្រីការិយាល័យពាហិរសាសនា
២៧-	លោក	គី ចិន្ត្រា	ប្រធានការិយាល័យធម្មការ និងសាសនាស្រុកស្វាយចេក
២៨-	លោក	យ៉ោក ឆៃយ៉ង់	ប្រធានការិយាល័យធម្មការ និងសាសនាស្រុកថ្មពួក
២៩-	លោកស្រី	ឈឹម គាន	មន្ត្រីការិយាល័យធម្មការ និងសាសនាស្រុកអូរជ្រៅ
៣០-	លោក	រី រិតធី	មន្ត្រីការិយាល័យពុទ្ធិកសិក្សា និងបណ្ណាល័យ
៣១-	លោក	ម៉ិក ដារ៉ា	មន្ត្រីការិយាល័យធម្មការ និងសាសនាក្រុងសិរីសោភ័ណ
៣២-	លោក	ព្រឿង រ៉ូ	មន្ត្រីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
៣៣-	លោក	អោម សំអុល	មន្ត្រីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
៣៤-	លោក	គិន សាន	មន្ត្រីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
៣៥-	វរសេនីយ៍ឯក	ឌុយ សាឌុន	អត្តលេខ ១៩៣៨២

មាត្រា ២._រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ៧១គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន ៧១រូប ដែលបានបរិច្ចាគបច្ច័យ ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តបន្ទាយមានជ័យ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

ក-មេដាយស្ថាបនាជាតិ

១-	ព្រះគ្រូមង្គលសិលាចារ្យ	**ឈោង សិជិក**	អនុគណស្រុកថ្មពួក
២-	ព្រះបញ្ញាបទីបោ	**យ៉ៅ ហើស**	ចៅអធិការវត្តពងសត្វ
៣-	ព្រះតេជគុណ	**ភាក់ ឃាន**	ចៅអធិការវត្តបារមីខ្នងទួល
៤-	ព្រះតេជគុណ	**សាត ម៉ាច**	ចៅអធិការវត្តពុទ្ធោអរហំ
៥-	ព្រះតេជគុណ	**អ៊ុំ ជឿន**	ចៅអធិការវត្តពុទ្ធមេត្តា
៦-	ព្រះតេជគុណ	**រ៉ា សុធា**	គង់នៅវត្តធម្មសណ្ឋាសពុទ្ធវិន័យ
៧-	ព្រះតេជគុណ	**ពិន ពឿន**	គ្រូសូត្រស្តាំវត្តធម្មសណ្ឋាសពុទ្ធវិន័យ
៨-	លោក	**ជា កៅ**	សប្បុរសជន ថវិកា ១២.០០០ ដុល្លារ
៩-	អ្នកស្រី	**ឃុំាង អួយលីន**	នាយិកាអង្គការហ្វ្រា ថវិកា ១១.១០០ ដុល្លារ
១០-	ឧបាសក	**សៀក យ៉ាន់**	សប្បុរសជន ថវិកា ១០.៥០០ ដុល្លារ
១១-	ឧបាសក	**សាយ ខ្មែម**	សប្បុរសជន ថវិកា ១០.០០០ ដុល្លារ
១២-	លោក	**លឹម ម៉េង**	សប្បុរសជន ថវិកា ១១.០០០ ដុល្លារ
១៣-	អ្នកស្រី	**អ៊ូ គិមមួយ**	សប្បុរសជន ថវិកា ១០.០០០ ដុល្លារ

១៤-	អ្នកស្រី	ផេង ឡៃហាំង	សប្បុរសជន ថវិកា ១០.០០០ ដុល្លារ
១៥-	លោក	ទង់ ប៊ូឃីង (WONG BOOK KING)	សប្បុរសជនព្រុយណេ ថវិកា ១២.០០០ ដុល្លារ
១៦-	លោក	ឆោម រ័ចង់	សប្បុរសជន ថវិកា ១០.៥០០ ដុល្លារ
១៧-	លោក	រាសី កុលវឌ្ឍន៍	សប្បុរសជន ថវិកា ១០.១០០ ដុល្លារ
១៨-	ឧបាសក	ហាម គិនសួន	សប្បុរសជន ថវិកា ១១.១៥០ ដុល្លារ
១៩-	ឧបាសិកា	យ៉ែម ណៃ	សប្បុរសជន ថវិកា ១២.២៧៧ ដុល្លារ
២០-	លោក	ស៊ុយ រិទ្ធ	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១០.៦០០ ដុល្លារ
២១-	លោក	ច្រាក់ សុផាត	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១៥.០០០ ដុល្លារ
២២-	លោក	ច្រាក់ សុផុន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១៤.២៥០ ដុល្លារ
២៣-	លោក	យង់ យីន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១០.០០០ ដុល្លារ
២៤-	លោក	ម៉ា ប៊ូ	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១០.០០០ ដុល្លារ
២៥-	លោក	សាយ សាវឿន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១០.០០០ ដុល្លារ
២៦-	លោក	ឡូន ឌុល	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១០.០០០ ដុល្លារ
២៧-	ឧបាសិកា	ជួន ហម	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ១០.០០០ ដុល្លារ
២៨-	លោក	ឃឹម ខេត	សប្បុរសជន នៅរាជធានីភ្នំពេញ
២៩-	លោក	ហ៊ឹម ហឿង	សប្បុរសជន នៅរាជធានីភ្នំពេញ
៣០-	លោក	ឃុត ខុម	សប្បុរសជន នៅរាជធានីភ្នំពេញ

ខ-មេដាយប្រាក់ស្ថាបនាជាតិ

១-	ព្រះសង្ឃប្បជ្ជោតោ	សំ វ៉ាន់ថា	គង់នៅវត្តគិរីធម្មបទខ្លាកូន
២-	ឧបាសិកា	ណៃ ចិន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៦.៥០០ ដុល្លារ
៣-	ឧបាសិកា	តាំង ម៉ែនហុង	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៦.០០០ ដុល្លារ
៤-	លោក	ឈិត សំណាង	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.២០០ ដុល្លារ
៥-	លោក	លីម សាមលី(LIM SAMLEE)	សប្បុរសជនព្រុយណេ ថវិកា ៥.៥០០ ដុល្លារ
៦-	លោក	យោ តុងលុក(YEO TIONG LOK)	សប្បុរសជនព្រុយណេ ថវិកា ៥.៥០០ ដុល្លារ
៧-	អ្នកស្រី	ច្រាក់ គាត	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.៦០០ ដុល្លារ
៨-	លោក	ច្រាក់ រិទ្ធ	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.៥០០ ដុល្លារ
៩-	លោក	ច្រាក់ របៀប	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.៤៥០ ដុល្លារ
១០-	លោក	ឌី សាលឿត	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.៤០០ ដុល្លារ
១១-	លោក	សឿន រ៉ាស៊ីន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.៣៥០ ដុល្លារ
១២-	លោក	ឆង ឈួត	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.២០០ ដុល្លារ
១៣-	លោក	នួន ទិច្ឆ័យ	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.១០០ ដុល្លារ
១៤-	លោក	ណាត នឿន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៥.៣៥០ ដុល្លារ
១៥-	ឧបាសក	ឃ្លោក ស៊ុន	គណៈកម្មការវត្តទូលព្រះធាតុ
១៦-	ឧបាសក	លុយ ជា	គណៈកម្មការវត្តទូលព្រះធាតុ
១៧-	ឧបាសក	ឌុច ឡឿន	គណៈកម្មការវត្តទូលព្រះធាតុ
១៨-	ឧបាសក	អែម ឌឹម	គណៈកម្មការវត្តទូលព្រះធាតុ

គ-មេដាយសិរីវឌ្ឍនស្ថាបនាជាតិ

១-	ព្រះបុញ្ញាធរោ	គូ សាយ័ន្ត	ចៅអធិការវត្តធម្មសុវណ្ណារាម ប្រាសាទបន្ទាយអំពិល
២-	លោក	លូសលី ថៅឆុង(LOUIS LEE THAU CHUNG)	សប្បុរសជនព្រៃយណេ ថវិកា ២.៥០០ ដុល្លារ
៣-	លោក	លីម កុកហ្គន់(LIM KOK GUAN)	សប្បុរសជនព្រៃយណេ ថវិកា ២.៥០០ ដុល្លារ
៤-	លោក	ឌឺរិលី តិចសាន់(DEREK LEE TET SHAN)	សប្បុរសជនព្រៃយណេ ថវិកា ២.៥០០ ដុល្លារ
៥-	អ្នកស្រី	វិនឌី អាយមុយធី (WINDY ANG MOITEE)	សប្បុរសជនព្រៃយណេ ថវិកា ២.៥០០ ដុល្លារ
៦-	អ្នកស្រី	ស្ទីហ្វានី ខូរាអានី(STIFANIE CORREANI)	សប្បុរសជនព្រៃយណេ ថវិកា ២.៥០០ ដុល្លារ
៧-	អ្នកស្រី	លីតិច លាន(LEE TECK LIAN)	សប្បុរសជនព្រៃយណេ ថវិកា ២.៥០០ ដុល្លារ
៨-	លោក	ប៉េន ហាម	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ២.៤០០ ដុល្លារ
៩-	លោក	ណារាត ណារិន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ២.៥០០ ដុល្លារ
១០-	លោក	ហ៊ា រិត	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ២.៥០០ ដុល្លារ
១១-	អ្នកស្រី	ឌុន យ៉ីន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ២.៥០០ ដុល្លារ
១២-	អ្នកស្រី	ប្រាក់ ឃាន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ២.៥០០ ដុល្លារ
១៣-	លោក	លេស សួន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៣.៥០០ ដុល្លារ
១៤-	លោក	ឱន រ៉ឺន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៣.៣០០ ដុល្លារ
១៥-	លោក	ថោង តួន	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៣.២០០ ដុល្លារ
១៦-	លោក	ឆោម រ៉ុំ	សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកា ៣.០០០ ដុល្លារ
១៧-	លោក	កែវ យ៉ន	ប្រធានអនុសាខាសមាគមន៍អាចារ្យខ្មែរស្រុកម៉ាឡៃ
១៨-	លោក	ឡាំ យឿន	អនុប្រធានសាខាសមាគមន៍អាចារ្យខ្មែរស្រុកមង្គលបុរី
១៩-	លោក	ជា សេងសារុន	អនុប្រធានអនុសាខាសមាគមន៍អាចារ្យខ្មែរក្រុងប៉ោយប៉ែត
២០-	លោក	ជា ទី	អនុប្រធានអនុសាខាសមាគមន៍អាចារ្យខ្មែរស្រុកម៉ាឡៃ
២១-	លោក	ឈីន ម៉ៅ	លេខាធិការអនុសាខាសមាគមន៍អាចារ្យខ្មែរស្រុកមង្គលបុរី
២២-	លោក	រស់ ដុំ	លេខាធិការអនុសាខាសមាគមន៍អាចារ្យខ្មែរស្រុកមង្គលបុរី
២៣-	លោក	ឃឿន សំបូរ	លេខាធិការអនុសាខាសមាគមន៍អាចារ្យខ្មែរស្រុកព្រះនេត្រព្រះ

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-បំពាក់ **មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ** ចំនួន ២៤គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន ២៤រូប ដែលបានបរិច្ចាគបច្ច័យ ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅខេត្តបន្ទាយមានជ័យ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

១-	ព្រះគ្រូឧសភាភោ	**រិត ស៊ីធីម**	ចៅអធិការវត្ត
២-	ឯកឧត្តម	**តាំង សេទិនអ៊ប**	សប្បុរសជននៅរាជធានីភ្នំពេញ
៣-	ឯកឧត្តម	**អ៊ុក សុខ**	សប្បុរសជននៅរាជធានីភ្នំពេញ
៤-	លោក	**អៀម សុខពិនី**	សប្បុរសជននៅរាជធានីភ្នំពេញ
៥-	លោក	**ឃិន សុផល**	សប្បុរសជន
៦-	ឧត្តមសេនីយ៍ត្រី	**សាន់ ប៊ុនធីន**	អត្តលេខ ១០៩៣២៨
៧-	ឧត្តមសេនីយ៍ត្រី	**ឈឹម សុវណ្ណា**	អត្តលេខ ២៣២៣១៥
៨-	ឧត្តមសេនីយ៍ត្រី	**ម៉ែន រស្មី**	អត្តលេខ ៥៤៨២៣
៩-	វរសេនីយ៍ទោ	**ទ៉ា ប្រុស**	អត្តលេខ ១៦៨០៩៩
១០-	វរសេនីយ៍ត្រី	**អ៊ឹម ស**	អត្តលេខ ០៩៥៧៤ អធិការរងស្រុកអូរយ៉ាដាវ
១១-	វរសេនីយ៍ត្រី	**ខយ ជន**	អត្តលេខ ១៧១៧២ អធិការរងស្រុកអូរយ៉ាដាវ
១២-	វរសេនីយ៍ត្រី	**រម្យ សុធា**	សប្បុរសជន នៅខេត្តកំពត
១៣-	វរសេនីយ៍ត្រី	**កែវ យុន**	សប្បុរសជន នៅខេត្តកំពត

១៤-	អនុសេនីយ៍ឯក	**ម៉ែន បូរាណ**	អត្តលេខ ៦២៩៣៧
១៥-	អនុសេនីយ៍ឯក	**ម៉ែន ពណ្ណរាយ**	សប្បុរសជន
១៦-	អនុសេនីយ៍ឯក	**អ៊ុក ចាន់ធឿន**	អត្តលេខ ៣២៨១៦
១៧-	អនុសេនីយ៍ទោ	**ចាន់ បញ្ញា**	អត្តលេខ ៧២១០២
១៨-	អនុសេនីយ៍ទោ	**ធឿន ទាសនា**	សប្បុរសជន
១៩-	អនុសេនីយ៍ទោ	**យី សុភាព**	អត្តលេខ ២៨៥០៤
២០-	អនុសេនីយ៍ទោ	**សែម មី**	អត្តលេខ ៦២៤៣៧
២១-	លោក	**ទៀម ចាន់បូណា**	សប្បុរសជន នៅខេត្តសៀមរាប
២២-	លោក	**ចាន់ សុគុណ**	ប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ
២៣-	អនុសេនីយ៍ឯក	**សៀក សុវណ្ណ**	អត្តលេខ ៣៨៣២៨
២៤-	អនុសេនីយ៍ឯក	**សាន សុគ៌ន្ធ**	អត្តលេខ ០៨៤៧៦៧

មាត្រា ២.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១..បំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សាលាឆាន់ និងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តសំបួរមាស ឃុំកំពង់ហៅ ស្រុកកំពង់លែង និងកសាងផ្លូវលូ ស្ពាន ស្ថិតនៅក្នុងឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

១-ព្រះតេជគុណ	**មួង សាម៉ុំ**	ព្រះចៅអធិការវត្តស្តីសិរីមង្គល	បច្ច័យចំនួន	១២.០៧៩ ដុល្លារ
២-ព្រះតេជគុណ	**ធេព សុផានី**	គង់នៅវត្តសារាវ័នតេជោ រាជធានីភ្នំពេញ	បច្ច័យចំនួន	១១.៧៧៩ ដុល្លារ
៣-ព្រះតេជគុណ	**អ៊ុន ដេត**	គង់នៅវត្តគល់ទទឹង ខេត្តកណ្តាល	បច្ច័យចំនួន	១១.៧៧៩ ដុល្លារ
៤-ព្រះតេជគុណ	**យៀក សាលឿន**	ព្រះចៅអធិការវត្តសំបួរមាស	បច្ច័យចំនួន	១០.០០០ ដុល្លារ
៥-ឧបាសិកា	**សៀក ឆេងហ៊ុន**	សប្បុរសជនខ្មែរ នៅប្រទេសបារាំង	ថវិកាចំនួន	៧៨.១១៦ ដុល្លារ
៦-ឧបាសិកា	**ទឹម ស៊ូអេង**	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន	១១.៧៧៩ ដុល្លារ
៧-ឧបាសិកា	**សៀក ឆេងជ្រា**	សប្បុរសជនខ្មែរ នៅប្រទេសបារាំង	ថវិកាចំនួន	១០.០០០ ដុល្លារ
៨-ឧបាសិកា	**លឹម ជាឡាង**	សប្បុរសជនខ្មែរ នៅប្រទេសបារាំង	ថវិកាចំនួន	១០.០០០ ដុល្លារ
៩-លោក	**លី រតនៈ**	សប្បុរសជនខ្មែរ នៅប្រទេសបារាំង	ថវិកាចំនួន	១០.០០០ ដុល្លារ
១០-លោក	**សៀក អៀមអៀង**	សប្បុរសជន នៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន	១០.០០០ ដុល្លារ

មាត្រា២.. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៥៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមាសការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១._

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្តល់ជូនមន្ត្រីរាជការចំនួន ០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តចំនួន ០៥ ស្ថិតនៅក្នុងស្រុករមាសហែក ស្រុកកំពង់រោទិ៍ និងស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលមានរាយនាមដូចខាងក្រោម ៖

១- លោកអនុសេនីយ៍ឯក **សែម ស៊ីណា**	នាយផ្នែកស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ
២- លោកអនុសេនីយ៍ទោ **ម៉ាន ឃុនហួរ**	នាយផ្នែកស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ
៣- លោកអនុសេនីយ៍ទោ **ព្រាប ចាន់**	នាយរងប៉ុស្តិ៍អន្លង់ជ្រៃ
៤- លោកអនុសេនីយ៍ទោ **ឃុត គា**	នាយរងប៉ុស្តិ៍អន្លង់ជ្រៃ
៥- លោកអនុសេនីយ៍ទោ **ប៊ុន សុផល**	នាយរងប៉ុស្តិ៍សូទៃ
៦- កញ្ញា **ម៉ាន ស្រីពៅ**	ជំនួយការឯកឧត្តមអគ្គលេខាធិការក្រសួងមហាផ្ទៃ

មាត្រា ២._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តតុណ្ឌបព្វតារាម ហៅ (វត្តភ្នំចំពុះ) ស្ថិតនៅឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមាននាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

-លោក **ឡឹង សុភាព** ប្រធានការិយាល័យគយនិងរដ្ឋាករខេត្តកំពង់ឆ្នាំង ថវិកាចំនួន ៦៤.៥០០ដុល្លារ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

-លោក **យ៉ង់ សៅវុឌ្ឍី** អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ខេត្តកំពង់ឆ្នាំង ថវិកាចំនួន ៣២.៧៧០ដុល្លារ

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៥៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១..បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តពុទ្ធិបព្វតារាម ប៉ោ (វត្តភ្នំចំពុះ) ស្ថិតនៅឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ

១-លោក **ឈួន ស៊ីវិន**	នាយករដ្ឋបាលសាលាដំបូងខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ១៦.០០០ ដុល្លារ
២-លោក **ពិន ថន**	សប្បុរសជន នៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ១៥.៥០០ ដុល្លារ
៣-ឧបាសិកា **សេខ ឌីវ**	សប្បុរសជន នៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ១៥.០០០ ដុល្លារ
៤-អ្នកស្រី **មាស សុខា**	សប្បុរសជន នៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ១៤.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ

-លោក **អ៊ុំ ច័ន្ទថា** នាយកសាលាបឋមសិក្សា **ប៊ុន រ៉ានី ហ៊ុន សែន** ព្រៃខ្មែរ ខេត្តកំពង់ឆ្នាំង ថវិកាចំនួន ៥.៣៥០ដុល្លារ

គ-មេដាយសំរិទ្ធស្ថាបនាជាតិ

-លោក **ហង់ គឹមសេត** សាស្ត្រាចារ្យវិទ្យាល័យ **ប៊ុន រ៉ានី ហ៊ុន សែន** រលាប្អៀរ ខេត្តកំពង់ឆ្នាំង ថវិកាចំនួន ៥.៣៥០ដុល្លារ

មាត្រា២..រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៦០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១. បំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន២២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តថ្មកែវ ស្ថិតនៅឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

១-ព្រះតេជគុណ	ស៊ុន ហួយ	ព្រះចៅអធិការវត្តថ្មកែវ	បច្ច័យចំនួន ១៣.០០០ ដុល្លារ
២-ឧបាសិកា	តុន ហ្គេចបួយ	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៤៩.៩៦០ ដុល្លារ
៣-ឧបាសិកា	សេង សៀកហេង	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ៤៨.០០០ ដុល្លារ
៤-ឧបាសក	ចាយ ពេជ្រ	សប្បុរសជន នៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ៣៤.៤០០ ដុល្លារ
៥-ឧបាសិកា	ហ្គេច ហួយ	សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក	ថវិកាចំនួន ២៦.៥០០ ដុល្លារ
៦-ឧបាសិកា	ជាង ណៃស៊ីម	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ២៤.៧៥០ ដុល្លារ
៧-ឧបាសក	មិន សាមឿន	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ២៣.៥០០ ដុល្លារ
៨-លោក	មិន សុវណ្ណា	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ២៣.៤០០ ដុល្លារ
៩-ឧបាសក	ហ៊ិន ហឿង	សប្បុរសជន នៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ១៣.០០០ ដុល្លារ
១០-លោក	អ៊ឹង លាងប៊ុច	សប្បុរសជន នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១២.៥០០ ដុល្លារ
១១-លោក	ឯម សោមុន្នី	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ១២.២៣០ ដុល្លារ
១២-ឧបាសិកា	អ៊ុំ ហ្គេចឡាយ	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ១១.៥០០ ដុល្លារ
១៣-ឧបាសក	ង៉ាង ឡៃស្រី	សប្បុរសជន នៅរាជធានីភ្នំពេញ	ថវិកាចំនួន ១១.៣០០ ដុល្លារ
១៤-លោក	សាយ ឈាន	ប្រធានគណៈកម្មការវត្តថ្មកែវ	ថវិកាចំនួន ១១.០០០ ដុល្លារ
១៥-លោក	ទូច ទឹម	អាចារ្យវត្តថ្មកែវ	ថវិកាចំនួន ១១.០០០ ដុល្លារ

១៦-លោក	ឃិន សំអុល	គណៈកម្មការវត្តថ្មកែវ	ថវិកាចំនួន ១១.០០០ ដុល្លារ
១៧-លោក	មុំ ធឿន	អាចារ្យវត្តថ្មកែវ	ថវិកាចំនួន ១១.០០០ ដុល្លារ
១៨-លោក	ឃី យ៉ាន	គណៈកម្មការវត្តថ្មកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ
១៩-លោក	ឡាយ យ៉ុង	អនុប្រធានភូមិថ្មកែវ	ថវិកាចំនួន ១០.៥០០ ដុល្លារ
២០-លោក	ឡាំ សារុន	សប្បុរសជននៅខេត្តកំពង់ឆ្នាំង	ថវិកាចំនួន ១០.៣៤០ ដុល្លារ
